**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ:

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**គោរពជូន**
**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា**
**អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពី នីតិវិធី ការទទួល និងផ្តល់សេវាជូនជនរងគ្រោះ និងងាយរងគ្រោះក្នុងមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ)។

**យោង** ៖ លិខិតចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ របស់អង្គការសហប្រជាជាតិ (UNCT)ប្រចាំនៅកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកជំទាវ** មេត្តាជ្រាបថា នៅក្នុងព្រឹត្តិការណ៍ "សហគមន៍ ២០កុម្ភៈ" ឆ្នាំ២០២១ រដ្ឋបាលរាជធានីភ្នំពេញ បានដាក់ចេញនូវវិធានការនានា សំដៅបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ "សហគមន៍ ២០កុម្ភៈ ២០២១" នៅរាជធានីភ្នំពេញ ដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងផ្អាករាល់ការជួបជុំ ឬប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដូចជា៖ ការផ្អាកគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន អាជីវកម្មក្លឹបកម្សាន្តគ្រប់ប្រភេទ ជាអាទិ៍ ខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន និងកាស៊ីណូ រមណីយដ្ឋាន សារមន្ទីរ សួនកុមារ និងសួនកម្សាន្តនានា អាជីវកម្មម៉ាស្សា សូណា ស្ទីមគ្រប់ប្រភេទ ហាងលក់ និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ រោងភាពយន្ត រោងសម្តែងសិល្បៈ ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកីឡាគ្រប់ប្រភេទ ពិសេសរហូតដល់បិទរាជធានីភ្នំពេញ ពុំឱ្យមានចរាចរណ៍ទៀតផង។ ដោយឡែកចំពោះនារីរកស៊ីផ្លូវភេទ និងជនអនាថា ក៏ជាកត្តាចម្លងជំងឺកូវីដ-១៩មួយផងដែរទើបរដ្ឋបាលរាជធានីភ្នំពេញណែនាំឱ្យអាជ្ញាធរខណ្ឌ ចុះរៀបចំសណ្តាប់ធ្នាប់ និងប្រមូលពួកគាត់ទៅនៅមណ្ឌលព្រៃស្ពឺ ជាក់ស្តែងរដ្ឋបាលខណ្ឌដូនពេញ បានធ្វើការរៀបចំសណ្តាប់ធ្នាប់ និងសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បានយកនារីដែលរកស៊ីផ្លូវភេទ និងជនអនាថាមួយចំនួនទៅធ្វើតេស្តស្វែងរកជំងឺកូវីដ-១៩នៅវិទ្យាល័យ ហ៊ុនសែនប៊ុនរ៉ានី វត្តភ្នំ។ ក្រោយពីចប់ការធ្វើចត្តាឡីស័ករដ្ឋបាលរាជធានីភ្នំពេញបានបញ្ជូនពួកគេទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ដើម្បីទទួលយកសេវាដែលផ្តល់ដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ រៀបចំនីតិវិធីក្នុងការបញ្ជូនពួកគាត់ទៅក្រុមគ្រួសារ ឬទៅអង្គការដៃគូរ ដែលនេះជាសកម្មភាពមនុស្សធម៌មួយក្នុងការការពារអាយុជីវិតអ្នករកស៊ីផ្លូវភេទ និងជនអនាថាអោយចៀសផុតពីជំងឺកូវីដ-១៩។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បានកំពុងដំណើរការទទួលសង្គ្រោះជនរងគ្រោះ និងជនងាយរងគ្រោះ ក្នុងនោះជនវ័យចាស់ជរាគ្មានទីពឹង ទុគ៌តជន ជនអនាថា ជនវិបល្លាសស្មារតី ជនពិការគ្មានទីពឹង អ្នកសុំទាន ស្ត្រីរកស៊ីផ្លូវភេទគ្មានសុវត្ថិភាព និងស្ត្រីរងគ្រោះដោយអំពើជួញដូរផ្លូវភេទក្នុងរាជធានីភ្នំពេញ សរុបចំនួន ៣៣៧នាក់ (ស្រី ១៤១នាក់) ដើម្បីផ្តល់ការហូបចុក ស្នាក់នៅអប់រំស្តារនីតិសម្បទា និងស្វែងរកគ្រួសារដែលពួកគេបានធ្វើចំណាកស្រុកប្រថុយប្រថានធ្វើសកម្មភាពលើមុខរបរប្រកបដោយហានិភ័យខ្ពស់ក្នុងទីប្រជុំជនរាជធានីភ្នំពេញ ដែលជាទីកន្លែងពោរពេញទៅដោយការអភិវឌ្ឍន៍ និងស៊ីវិល័យស្រស់ឆើតឆាយ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បាននិងកំពុងអនុវត្តន៍ដំណើរការមជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ) ស្របតាមការដឹកនាំដ៏ខ្ពង់ខ្ពស់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមការណែនាំលក្ខណៈបច្ចេកទេសត្រឹមត្រូវ បទដ្ឋានថែទាំជនរងគ្រោះ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រសកម្មភាពយ៉ាងពេញលេញពីរដ្ឋបាលរាជធានីភ្នំពេញ អំពីនីតិវិធី ការទទួល និងផ្តល់សេវាជូនជនរងគ្រោះ និងជនងាយរងគ្រោះក្នុងមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ)។

មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ ស្ថិតក្នុងភូមិស្រែជំរៅ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានអគារទីចាត់ការ០១ខ្នង អគារពិគ្រោះយោបល់០១ខ្នង ប៉ុស្តិ៍សុខភាព ០១ខ្នង អគារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ០១ខ្នង អគារស្នាក់នៅជនរងគ្រោះ និងជនងាយរងគ្រោះ ០៣ខ្នង (អគារបុរស ០២ខ្នង និងផ្នែកនារី ០១ខ្នង) សាលប្រជុំ០១ អគាររោងបាយ និងដាំបាយ០១ខ្នង។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញបានផ្តល់សេវាចាំបាច់មួយចំនួនដែលផ្តល់អត្ថប្រយោជន៍ជូនជនរងគ្រោះ និងជនងាយរងគ្រោះរួមមាន៖

- ទទួលសង្គ្រោះជនរងគ្រោះ និងជនងាយរងគ្រោះពីតាមបណ្តាខណ្ឌ ដែលបានបញ្ជូនមកដោយផ្តល់ការស្នាក់នៅ ទទួលអាហារហូបចុក០៣ពេលក្នុង០១ថ្ងៃ បង្អែម០១ដងក្នុង០១សប្តាហ៍
- បែងចែកប្រភេទជនរងគ្រោះ និងជនងាយរងគ្រោះប្រុស-ស្រី (ដាក់ដាច់ដោយឡែកពីគ្នា)
- ពិគ្រោះយោបល់ស្វែងរកគ្រួសារសាច់ញាតិ ដើម្បីប៉ាន់ប្រមាណធ្វើផែនការសមាហរណកម្មទៅក្រុមគ្រួសារវិញ និងថតរូបបំពេញឯកសារ កំណត់អត្តសញ្ញាណ បញ្ចូលទិន្នន័យជនរងគ្រោះ ទៅតាមទម្រង់នីមួយៗ
- អប់រំ ផ្សព្វផ្សាយ ដល់ជនរងគ្រោះ និងជនងាយរងគ្រោះ អំពីផលប៉ះពាល់បញ្ហាប្រឈមនានាដែលបណ្តាលមកពីមុខរបរគ្មានសុវត្ថិភាព

+ចំពោះករណីអ្នកសុំទាន និងស្ត្រីរកស៊ីផ្លូវភេទ គឺមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញបាន៖

- បញ្ជូនជនរងគ្រោះ ទៅព្យាបាលតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋនានា នៅពេលមានជំងឺធ្ងន់ធ្ងរ និងបន្ទាន់
- ផ្តល់កម្មវិធីហាត់ប្រាណដើម្បីសុខភាព កម្មវិធីសូត្រធម៌អប់រំផ្លូវចិត្ត និងកម្មវិធីបណ្តុះបណ្តាលជំនាញ

- មានបុគ្គលិកប្រចាំការដើម្បីមើលថែ និងបញ្ជូនជនរងគ្រោះ និងជនងាយរងគ្រោះ ទៅមន្ទីរពេទ្យនៅពេលដែលមានជំងឺ និងការយកចិត្តទុកដាក់ ផ្គត់ផ្គង់ម្ហូបអាហារប្រកបដោយគុណភាព
- យកចិត្តទុកដាក់ និងសហការជាមួយគ្រូពេទ្យផ្នែកព្យាបាលជំងឺក្នុងការព្យាបាលដល់ជនរងគ្រោះ និងជនងាយរងគ្រោះ តាមបន្ទប់ស្នាក់នៅ (គ្រូពេទ្យបញ្ជូនមកពីមន្ទីរសុខាភិបាលរាជធានីភ្នំពេញ)
- មានកម្មវិធីសួរសុខទុក្ខពីសំណាក់សាច់ញាតិជនរងគ្រោះ និងជនងាយរងគ្រោះ បានស្វែងរកឃើញ
- រៀបចំផែនការជំនាញពិតប្រាកដ និងបញ្ជូនបន្តទៅរកសេវា ចាំបាច់ពីអង្គការដៃគូអភិវឌ្ឍន៍ ដើម្បីពួកគេទទួលបាននូវអត្ថប្រយោជន៍ខ្ពស់ និងធ្វើសមាហរណដល់ជនរងគ្រោះ និងជនងាយរងគ្រោះ ដែលបានស្វែងរកបងប្អូនឃើញ អប់រំបញ្ជូនពួកគេឱ្យត្រឡប់ទៅក្រុមគ្រួសារ និងសហគមន៍វិញ
- សហការជាមួយមន្ទីរស.អ.យ ដើម្បីសមាហរណកម្មជនរងគ្រោះ ឱ្យត្រឡប់ទៅតាមបណ្តាខេត្តនានាវិញ (ករណីជនរងគ្រោះ និងជនងាយរងគ្រោះមកពីតាមបណ្តាខេត្ត)។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ** មេត្តាជ្រាបជាសេចក្តីរាយការណ៍។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពពីខ្ញុំ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ និងជា**
**ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្សរាជធានីភ្នំពេញ**

<u>ចម្លងជូន៖</u>
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  <u>"ដើម្បីជូនជ្រាប"</u>
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ
  <u>"ដើម្បីជ្រាប"</u>
- ឯកសារ-កាលប្បវត្តិ